# ចៅក្រមនៅចំពោះមុខខ្មែរក្រហម[១]

*“អ្វីដែលសំខាន់គឺ ហេតុអ្វីបានជាបុគ្គលទាំងនោះជាប់នៅទីនេះ ។”*

– Jacques Sémelin, Purifier et Détruire.

*ដោយ ម៉ាកសែល ឡឺម៉ុង ជាមួយនឹង ហ្សង់ រ៉េណូត*[២]

*បន្ទាប់ពីធ្វើការស៊ើបអង្កេតអស់រយៈពេលជិតមួយឆ្នាំ សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ម៉ាកសែល ឡឺម៉ុង និង យូ ប៊ុនឡេង បានបញ្ជូន កាំង ហ្គេកអ៊ាវ ហៅ ឌុច ទៅកាត់ទោសចំពោះបទចោទប្រកាន់ទាក់ទងនឹងការស្លាប់របស់ប្រជាជនយ៉ាងហោចណាស់ចំនួន ១២,២៧២នាក់ នៅក្នុងមន្ទីរសន្តិសុខស-២១ រួមមានទាំង បុរស ស្ត្រី និងកុមារ ។*[៣] *ចំណុចនេះដកស្រង់ចេញពីឯកសារជំនួយស្មារតីរបស់ចៅក្រម ឡឺម៉ុង ដែលនិយាយអំពីបទពិសោធន៍នៃការបម្រើការងារអស់រយៈពេលជាងបួនឆ្នាំនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ លោកចៅក្រមបានរៀបរាប់ពីទស្សនៈផ្ទាល់ខ្លួនពាក់ព័ន្ធនឹង ឌុច ពេលដែលលោកធ្លាប់បានធ្វើការស៊ើបអង្កេត អំពីចរិតលក្ខណៈនៃការទទួលខុសត្រូវរបស់ ឌុច ទៅលើឧក្រិដ្ឋកម្មដែលបានកើតឡើងនៅស-២១ និងទីតាំងដែលពាក់ព័ន្ធផ្សេងទៀត ។*

## ជំពូកទី១៩

*ខែមីនា ឆ្នាំ២០០៨*

---

[១] *អ្នកនិពន្ធបានយល់ព្រមឲ្យ ទីហ្វានី ហ្វ៊ីរី* (Tiphaine Ferry) *និង អាញ ហែនឌល* (Anne Heindel) *បកប្រែអត្ថបទដកស្រង់មួយនេះដែលស្រង់ចេញពី* Un Juge Face Aux Khmers Rouges (Paris, Seuil 2013) ។

[២] *លោកចៅក្រមជនជាតិបារាំង ម៉ាកសែល ឡឺម៉ុង* (Marcel Lemonde) *គឺជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចាប់ពីឆ្នាំ២០០៦ ដល់ឆ្នាំ២០១០ ។ នៅក្នុងអំឡុងពេលដែលលោកចៅក្រម ឡឺម៉ុង បម្រើការងារការិយាល័យសហចៅក្រមស៊ើបអង្កេត បានចេញដីកាដំណោះស្រាយពីរដើម្បីធ្វើការចោទប្រកាន់អតីតមេដឹកនាំខ្មែរក្រហមចំនួនប្រាំរូបអំពីឧក្រិដ្ឋកម្មអន្តរជាតិ ។ រហូតមកដល់សព្វថ្ងៃនេះ មេដឹកនាំខ្មែរក្រហមទាំងប្រាំនោះ គឺជាបុគ្គលដែលត្រូវបានចោទប្រកាន់ដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ លោកមេធាវី ហ្សង់ រ៉េណូត* (Jean Reynaud) *គឺជាសហនិពន្ធនៃខ្សែភាពយន្តឯកសារ ដែលមានចំណងជើងថា* “Khmer Rouge, A Simple Question of Justice” ។

[៣] *សូមមើល ដីកាដំណោះស្រាយ លេខ* 001/18-07-2007-ECCC-OCIJ *(ថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៨)* ។

សួស នៅ ហៅ ឈូក គឺជាជននិយមកណ្តាល និងអង់អាចក្លាហានមួយរូបរបស់ខ្មែរក្រហម ។ នៅដំណាក់កាលដំបូងនៃរបបខ្មែរក្រហម នៅ គឺជាបុគ្គលមួយរូបដែលបានប្រឆាំងនឹងការសម្លាប់ដែលមានលក្ខណៈជាប្រព័ន្ធទៅលើអ្នកដែលគាំទ្ររបបដឹកនាំរបស់ លន់ នល់ ។ មិនយូរប៉ុន្មាន ឈូក ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅកាន់មន្ទីរស-២១ នៅពេលដែល ឈូក មានតួនាទីជាលេខាភូមិភាគបូព៌ា ដែលកម្មាភិបាលភាគច្រើននៃភូមិភាគបូព៌ាត្រូវបានធ្វើវិសុទ្ធកម្ម ។ ឌុច ដែលមានតួនាទីជាប្រធានមន្ទីរស-២១ បានតាមឃ្លាំមើលយ៉ាងល្អិតល្អន់ចំពោះការសួរចម្លើយលើ ឈូក ។ ការិយាល័យសហចៅក្រមស៊ើបអង្កេតបានរកឃើញលិខិតមួយ ដែល ឌុច បានសរសេរទៅឲ្យ ឈូក នៅក្នុងអំឡុងពេលដែល ឈូក ស្ថិតនៅក្នុងមន្ទីរឃុំឃាំង ។ នៅក្នុងលិខិតនោះ ឌុច បានបញ្ជាក់ថា "គណៈកម្មាធិការ" នឹងបញ្ជាឲ្យសម្លាប់ ឈូក ប្រសិនបើ ឈូក នៅតែមិនព្រមសារភាពពីកំហុសរបស់ខ្លួន ។

នៅពេលដែលយើងបានបង្ហាញលិខិតនោះទៅកាន់ ឌុច ហើយបានសួរ ឌុច ថានរណាខ្លះនៅសមាជិកនៅក្នុង«គណៈកម្មាធិការ» ដែល ឌុច បានលើកឡើង? នៅពេលនោះ ឌុច បានផ្ទុះសំណើចឡើង ។ កែវភ្នែករបស់ ឌុច បានបង្កប់ទៅដោយភាពអស់សំណើច ។ ឌុច បាននិយាយថា «នេះគ្រាន់តែជាវិធីមួយ ដើម្បីបំភ័យអ្នកទោសតែប៉ុណ្ណោះ ។» ឌុច បានបញ្ជាក់ថា មិនមានគណៈកម្មាធិការ ឬការគម្រាមសម្លាប់ ឬការដាក់ខសានវាទនោះទេ ។ ប្រធានមន្ទីរស-២១ រូបនេះ បានបង្កើតកលល្បិចផ្សេងៗ ដើម្បីធ្វើយ៉ាងណាឲ្យអ្នកទោសឆ្លើយសារភាព ។ នៅពេលដែលយើងសួរចម្លើយ ឌុច គាត់ហាក់ដូចជាមិនមានភាពតក់ស្លុត ព្រមទាំងបានព្យាយាមនិយាយយករួចខ្លួន ។

ឈូក បានឆ្លើយសារភាពដូចអ្វីដែលអ្នកទោសផ្សេងទៀតបានឆ្លើយ ហើយដូចអ្នកទោសដទៃទៀតដែរ ឈូក ត្រូវបានគេយកទៅសម្លាប់ ។

យើងបានអង្គុយមើល និងចាំស្តាប់ពីចម្ងាយយ៉ាងយកចិត្តទុកដាក់នៅពេលដែល ឌុច បានរៀបរាប់ប្រាប់យើងអំពីការសម្លាប់ ឈូក ។ នៅម៉ោងប្រាំទៀបភ្លឺ នៅលើផ្លូវបែកជាបួនមិនឆ្ងាយប៉ុន្មានពីមន្ទីរឃុំឃាំង ឈូក ត្រូវបានចាក់សម្លាប់នឹងដែកគាំបិត ។ ឌុច បានមើលឃើញព្រឹត្តិការណ៍សម្លាប់នេះដោយភាពតក់ស្លុត ។

នៅពេលដែលយើងបន្តសួរ ឌុច អំពីព្រឹត្តិការណ៍សម្លាប់នោះ ឌុច បានចាប់អារម្មណ៍ថា ព្រឹត្តិការណ៍នោះបានរស់ឡើងវិញនៅពេលដែលគាត់ចាប់ផ្តើមរៀបរាប់ ។ ឌុច ហាក់ដូចជាស្រឡាំងកាំង ហើយភ្នែករបស់គាត់ហាក់ដូចជារុំព័ទ្ធទៅដោយអ័ក្រផ្សែង ។ មួយសន្ទុះក្រោយមក ឌុច បានដើរចេញពីយើង ។

នៅក្នុងអំឡុងពេលនៃការសួរចម្លើយ យើងបានបង្កើតនូវទំនាក់ទំនងដ៏ពិសេសមួយជាមួយ ឌុច ។ ខ្ញុំហាក់ដូចជាមានអារម្មណ៍ម្យ៉ាងចំពោះ ឌុច ។ អារម្មណ៍នោះមានឈ្មោះថា លីមាស៊ីនដ្រូម[៤] ជាអារម្មណ៍មួយដែលអ្នកគ្រប់គ្រងមន្ទីរឃុំឃាំងមានការអាណិតអាសូរដល់អ្នកជាប់ឃុំឃាំង ។ មិនយូរប៉ុន្មាន ខ្ញុំចាប់ផ្ដើមយល់ឃើញថា ប្រធានខាងធ្វើទារុណកម្មម្នាក់ដែលនៅចំពោះមុខខ្ញុំ គឺជាអ្នកទោសសាមញ្ញមួយរូបប៉ុណ្ណោះ ។ បើទោះបីជា ខ្ញុំមិនត្រូវបំភ្លេចពីឧក្រិដ្ឋកម្មដែល ឌុច ធ្លាប់បានប្រព្រឹត្ត ប៉ុន្តែខ្ញុំមើលមិនឃើញថា ឌុច ធ្លាប់ជាឧក្រិដ្ឋជននោះទេ ។ ជួនកាល ខ្ញុំមានអារម្មណ៍ថា បុរសម្នាក់ដែលនៅចំពោះមុខខ្ញុំ មានទាំងគុណសម្បត្តិ និងគុណវិបត្តិ មានទាំងភាពរួសរាយ និងភាពរំខាន ។ ក្រោយមកខ្ញុំយល់ឃើញថា ឌុច មិនមែនជាមនុស្សគួរឲ្យខ្លាចនោះទេ ។ ប៉ុន្តែ ការយល់ឃើញបែបនេះបានធ្វើឲ្យខ្ញុំចាប់ផ្ដើមខ្លាច ឌុច ។ កន្លងមក យើងហាក់ដូចជាចុះសម្រុងនឹងគ្នា ។ ឌុច ជាមនុស្សសុភាព និងតែងតែញញឹម ដែលនេះជាចរិតលក្ខណៈមួយខុសពីអសុរកាយ ។

ជាក់ស្ដែង ឌុច ធ្លាប់បានប្រព្រឹត្តនូវអំពើឃោរឃៅជាច្រើន ។ មានពេលខ្លះ ខ្ញុំបានសង្កេតឃើញពីភាពគួរឲ្យខ្លាចរបស់ ឌុច ដូចជា នៅពេលដែលគាត់សើចចេញធ្មេញជាដើម ។ ប៉ុន្តែ គាត់នៅតែបង្ហាញឲ្យខ្ញុំឃើញថា គាត់គឺជាមនុស្សសាមញ្ញមួយរូប ។ នេះប្រហែលជាមានន័យថា ឌុច គ្រាន់តែជាមនុស្សសាមញ្ញម្នាក់ ដែលត្រូវបានយកមកកាត់ទោស ។ បើទោះបីក្នុងករណីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក៏ដោយ ក៏យើងមិនចាំបាច់ចាត់ទុកជនជាប់ចោទថាជា "អសុរកាយ" នោះទេ ។ ខ្ញុំបានបង្ហាញពីការយល់ឃើញបែបនេះយ៉ាងពិស្ដារ នៅក្នុងបទសម្ភាសន៍របស់ខ្ញុំជាមួយទស្សនាវដ្ដីប្រចាំសប្ដាហ៍មួយឈ្មោះ ប៉ារីសម៉ាច ។[៥] បើទោះបីជាខ្ញុំបានព្យាយាមពន្យល់យ៉ាងណាក៏ដោយ ក៏ចំណងជើងរបស់អត្ថបទនោះបានដាក់ថា "អស់រយៈពេលជាង៣០ឆ្នាំកន្លងផុតទៅ នៅទីបំផុតអសុរកាយត្រូវបាននាំយកមកកាត់ទោស" ។

ជាការពិតទៅ បើទោះបីជាការកាត់ទោស ឌុច ត្រូវបានមើលឃើញថាមានជាប់ពាក់ព័ន្ធនឹងហេតុផលនយោបាយក៏ដោយក៏ប៉ុន្តែរបបមួយអាចដំណើរការទៅមុខបានដោយសារតែបុគ្គល ។យើងមិនអាចកាត់ផ្ដាច់ការពាក់ព័ន្ធជាមួយមនុស្សឲ្យចេញពីបញ្ហាដែលបានកើតឡើងនោះទេ ។ ដោយយោងលើហេតុផលនេះ យើងបានអញ្ជើញអ្នកជំនាញចិត្តសាស្ត្រពីររូបគឺ លោកសាស្ត្រាចារ្យ ប្រាំងស័រ ស៊ីរ៉ូនី ដែលជំនាញ ខាងជួយជនរងគ្រោះពីការធ្វើទារុណកម្ម និងអំពើយង់ឃ្នង និង លោកសាស្ត្រាចារ្យ ការស៊ុនប៊ុនណាត ដែលមានជំនាញខាងចិត្តសាស្ត្រ ដើម្បីប្រឹក្សាយោបល់អំពីបញ្ហានេះ ។

---

[៤] លីមាស៊ីនដ្រូម (Lima syndrome) ជាអារម្មណ៍មួយដែលអ្នកគ្រប់គ្រងមន្ទីរឃុំឃាំងមានការអាណិតអាសូរដល់អ្នកជាប់ឃុំឃាំង ។

[៥] ទស្សនាវដ្ដីប្រចាំសប្ដាហ៍ ប៉ារីសម៉ាច (*Paris Match*) ចុះថ្ងៃទី២០ខែវិច្ឆិកា ឆ្នាំ២០០៨ ។

នៅក្នុងរបាយការណ៍របស់អ្នកចិត្តសាស្ត្រទាំងពីររូបបានប្រគល់មកឲ្យយើង បន្ទាប់ពីបានធ្វើការសម្ភាសជាមួយអ្នកទោសអស់រយៈពេល៩០ម៉ោង បានបង្ហាញពីចរិតលក្ខណៈមួយចំនួនរបស់ ឌុច ។ ឌុច ធ្លាប់ជួបប្រទះនូវបញ្ហាអសន្តិសុខចម្បងៗមួយចំនួន ដែលជាហេតុបង្ខំឲ្យគាត់ចុះចូលជាមួយក្រុមណាដែលខ្លួនយល់ឃើញថាជាក្រុមដែលមានអំណាច ។ អ្វីដែល ឌុច យល់ឃើញថាល្អសម្រាប់ខ្លួននោះគឺការជ្រកកោនក្រោមស្ថាប័នធំៗពីរៈ ទីមួយ គឺស្ថាប័នយុត្តិធម៌អន្តរជាតិ ដែលបច្ចុប្បន្នកំពុងកាត់ទោសគាត់អំពីទង្វើដែលគាត់ធ្លាប់បានប្រព្រឹត្ត និងទីពីរ គឺស្ថាប័នគ្រិស្តសាសនា ។

សម្រាប់ ឌុច មិនមានអ្វីសំខាន់ជាងការទទួលស្គាល់ពីសំណាក់មេរបស់ខ្លួននោះទេ ។ ឌុច ប្រហែលជាមានការសោកស្តាយចំពោះឧក្រិដ្ឋកម្មដែលគាត់ធ្លាប់បានប្រព្រឹត្ត ប៉ុន្តែ គាត់មានមោទនភាពក្នុងការដែលគាត់អាចសម្រេចនូវរាល់ភារកិច្ចរបស់គាត់ ។ ការគិតរបស់ ឌុច នៅតែជិតដាមទៅដោយមនោគមវិជ្ជារបស់ខ្មែរក្រហម ។ ទំនាក់ទំនងរបស់ ឌុច ជាមួយនឹងថ្នាក់លើបានបង្ហាញយ៉ាងច្បាស់ពីការលើកឡើងមួយនេះ ។ តាមរយៈការសហការជាមួយយើង និងការឆ្លើយនូវសំណួររបស់យើងដោយការយកចិត្តទុកដាក់ ឌុច បានបង្ហាញឲ្យយើងឃើញថា ក្នុងនាមជាប្រធានមន្ទីរស-២១ៈ មេដឹកនាំគឺជាមនុស្សសំខាន់បំផុតសម្រាប់ ឌុច ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មេដឹកនាំទាំងនោះមាន សុន សេន និងបន្ទាប់មកគឺ នួន ជា ។ សម្រាប់ពេលបច្ចុប្បន្ន មេដឹកនាំដែល ឌុច គិតថាសំខាន់ គឺសហចៅក្រមស៊ើបអង្កេត ។ កាលពី៣០ឆ្នាំមុន ឌុច គឺជាប្រធានសន្តិសុខគំរូមួយរូប ។ បច្ចុប្បន្នក៏នៅតែដូច្នេះដែរ ឌុច តែងព្យាយាមបង្ហាញយើងឲ្យឃើញថា ខ្លួនគឺជាជនជាប់ចោទគំរូមួយរូប ។

យើងបានសួរទៅអ្នកជំនាញថា តើ ឌុច អាចទទួលរងប៉ះពាល់ការប៉ះទង្គិចផ្នែកផ្លូវចិត្ត ដូចជាវិកលចរិត រោគចិត្ត ឬការខូចចិត្តដែរឬទេ? អ្នកជំនាញបានអះអាងដោយប្រាកដប្រជាថា ឌុច មិនមានបញ្ហាទាំងអស់នោះទេ ។ បន្ទាប់ពីបានជួបជាមួយ ឌុច អស់រយៈពេលជាច្រើនខែ ខ្ញុំក៏មិនដែលសង្ស័យថា ឌុច បានជួបបញ្ហាដូចរៀបរាប់ខាងលើនោះទេ ។ បើទោះបីជា អតីតប្រធានមន្ទីរស-២១រូបនេះបានបង្ហាញសញ្ញាមួយចំនួន ដូចជា កង្វះការយល់ចិត្ត ឬកង្វះការរំជួលចិត្តក៏ដោយ ក៏បញ្ហានេះមិនបានបង្ហាញថាជារោគសញ្ញានៃជំងឺនោះទេ ។

ប៉ុន្តែ យើងបានដឹងរឿងរ៉ាវដ៏ឃោរឃៅមួយដោយចៃដន្យតាមរយៈការសម្ភាសន៍ ។ ឌុច បានចាត់ទុកភារកិច្ចខ្លួនគឺជាការកំសាន្ត ។ ឌុច ចូលចិត្តដើរទៅអគារជាន់ផ្ទាល់ដីនៅចំកណ្តាលមន្ទីរស២១ ជាទីតាំងដែលជាងគំនូរ និងជាងចម្លាក់កំពុងធ្វើកិច្ចការសិល្បៈសម្រាប់ ប៉ុល ពត និងរបបនោះ ។ ឌុច អង្គុយមើលការងារអ្នកទាំងនោះ ។ ថ្ងៃមួយ ឌុច បានហុចបារីមួយកញ្ចប់ទៅឲ្យ បូ ម៉េង ដែលកំពុងធ្វើការនៅទីនោះ ។ បន្ទាប់មក ឌុច បានបង្គាប់ឲ្យ បូ ម៉េង វាយ អៀម ចាន់ ជាជាងចម្លាក់ ដែលកំពុងធ្វើការនៅក្បែរគាត់ ដោយមិនដឹងពីមូលហេតុពិតប្រាកដ ។ បូ ម៉េង និង អៀម ចាន់ ចាប់ផ្តើមវាយគ្នា

ដោយប្រើបំពង់ជ័រនៅក្បែរនោះ នៅចំពោះមុខ ឌុច ។ នៅពេលដែលសួរ ឌុច ថាហេតុអ្វីបានជាគាត់ធ្វើបែបនេះ? ឌុច បានឆ្លើយថា គាត់មិនបានដឹងនោះទេ ។ បន្ទាប់មក គាត់បាននិយាយថា គាត់សុំពិភាក្សាបញ្ហានេះជាមួយបព្វជិត ។

អតីតប្រធានមន្ទីរស-២១ហាក់ដូចជាមានអត្តចរិតច្បាស់លាស់ជ្រុលហួសហេតុ ។ គាត់ គឺជាមនុស្សម្នាក់ដែលមានការប្រយ័ត្នប្រយែងខ្ពស់ និងទាមទារឲ្យការងារមានភាពត្រឹមត្រូវ ។ ឧទាហរណ៍ ឌុច បានស្នើឲ្យមានការកែប្រែលើកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីទាក់ទងនឹងចំណុចលម្អិតជាច្រើនដែលអ្នកផ្សេងទៀតពុំសូវចាប់អារម្មណ៍ ។ ឌុច យកចិត្តទុកដាក់ខ្លាំងទៅលើការទទួលបានការពិត ឬយ៉ាងហោចណាស់ភាពជាក់លាក់ ។

ទោះបីជា ឌុច យកចិត្តទុកដាក់ខ្លាំងលើការទទួលបានការពិតក៏ដោយ តែប្រព័ន្ធដែល ឌុច បានបង្កើតឡើង គឺបានពឹងផ្អែកលើអ្វីដែលផ្ទុយពីការពិត ។ ជាក់ស្តែង ការបង្ខំឲ្យអ្នកទោសឆ្លើយសារភាពដោយការធ្វើទារុណកម្ម បើទោះបីជា ឌុច បានដឹងថា ក្រោមការធ្វើទារុណកម្ម អ្នកទោសអាចនឹងនិយាយអ្វីផ្សេង ។ មិនតែប៉ុណ្ណោះ ឌុច បានបង្កើតប្រព័ន្ធមួយដែលពោរពេញទៅ ដោយភាពភ័យខ្លាចដូចជា ការចងក្រងបណ្តាញខ្មាំង ខ្សែក្បត់ និងការប៉ុនប៉ងសម្លាប់ តាមរយៈចម្លើយសារភាព បើទោះបីជា ចម្លើយសារភាពនោះមិនគួរឲ្យជឿជាក់មួយរយភាគរយក៏ដោយ ប៉ុន្តែទាំងអស់នេះ គឺជាអ្វីដែលមេដឹកនាំចង់បាន ។

ហេតុអ្វីបានជា ឌុច ខ្វល់ខ្វាយខ្លាំងអំពីភាពជាក់លាក់ត្រឹមត្រូវ? ថ្ងៃមួយ ខ្ញុំបានសួរ ឌុច ថា «អ្នកបានទទួលស្គាល់ថា អ្នកបានដឹងតាំងពីដំបូងម៉្លេះថាចម្លើយសារភាពទាំងនោះមិនបានឆ្លុះបញ្ចាំងពីការពិតនោះទេ ។ តើនេះមិនមែនមានន័យថា អ្នកបានបញ្ជូនមនុស្សរាប់ពាន់នាក់ទៅសម្លាប់ចោល ទាំងដឹងថាអ្នកទាំងអស់នោះមិនបានធ្វើខុសទេឬ? ឬមួយ អ្នកពុំមានឱកាសរត់គេចខ្លួនដូចមនុស្សដទៃដែលមានឋានៈប្រហាក់ប្រហែលនឹងអ្នក?»

ឌុច មិនបានបកស្រាយអំពីសំណួរដំបូងដែលបានលើកឡើងខាងលើនោះទេ ។ ប៉ុន្តែ ឌុច បាននិយាយថា «ខ្ញុំមិនមានសិទ្ធិដកនរណាម្នាក់ចេញបានទេ ។ ថ្នាក់លើជាអ្នកមើលការខុសត្រូវពីលើ ។ ជាងនេះទៅទៀត កម្មាភិបាលដែលអាចរត់គេចខ្លួនរួច គឺជាក្រុមដែលប្រយុទ្ធជាមួយវៀតណាមនៅតាមព្រំដែន... ។»

ទោះបីជាយ៉ាងណាក៏ដោយឌុចបានបញ្ជូនមនុស្សដែលគាត់ដឹងថាមិនមានកំហុសយកទៅសម្លាប់ ។ នេះគឺជារឿងដែលមិនអាចប្រកែកបាន ។ មិនតែប៉ុណ្ណោះ ឌុច ពុំបានប្រកែកចំពោះការលើកឡើងបែបនេះទេ ។

របៀបដែល ឌុច ធ្វើការ បានធ្វើឲ្យយើងនឹកឃើញអំពី អៃក្មាន់ ។[៦] ជាការពិត ឌុច និង អៃក្មាន់ មានបុគ្គលិកលក្ខណៈខុសគ្នា ។ អៃក្មាន់ ប្រហែលជាបង្ករ និងគិតគូរពីអាជីពជាង ឌុច ។ ប៉ុន្តែ នៅក្នុងនាមជាជនជាប់ចោទ អ្នកទាំងពីរហាក់ដូចជាមានភាពស្រដៀង ដែលគួរឲ្យកត់សម្គាល់ ។ យើងអាចនិយាយបានថា អ្នកទាំងពីរមានប្រតិកម្មតបស្រដៀងគ្នា សូម្បីតែភាសាដែលអ្នកទាំងពីរបានប្រើ ។ ជាងនេះទៅទៀត អ្នកទាំងពីរមិនមានបញ្ហាផ្នែកស្មារតីនោះទេ ។

ឌុច ត្រូវបានកេណ្ឌឲ្យចូលបម្រើការងារដែលគាត់មិនចូលចិត្ត ។ ក្រោយមក ឌុច ត្រូវចាត់តាំងឲ្យធ្វើជាប្រធានមន្ទីរស២១ ដោយសារតែគាត់ធ្លាប់មានបទពិសោធន៍ធ្វើជាប្រធានមន្ទីរម១៣ ។[៧] ឌុច បានពន្យល់ថា គាត់ហាក់ដូចជាស្ទាក់ស្ទើរក្នុងការទទួលយកការចាត់តាំងពីថ្នាក់លើ ។ គាត់ធ្លាប់បានសុំថ្នាក់លើឲ្យជ្រើសតាំងអ្នកថ្មីមកជំនួសគាត់ ។ បើនិយាយពី អៃក្មាន់ វិញ គាត់បានអះអាងខ្លួនថា "គាត់បានប្រឆាំងដាច់ខាតចំពោះការប្រព្រឹត្តិអំពើហិង្សាទៅលើជនជាតិជ្វីហ" និងជាអ្នកគាំទ្រការបង្កើតរដ្ឋជ្វីហនៅប្រទេសអ៊ីស្រាអែល ដែលហៅជាភាសាអង់គ្លេសថា "ហ្សៃអូនីស៊ឹម" ។[៨] ប៉ុន្តែ សតិសម្បជញ្ញៈនៃការទទួលខុសត្រូវរបស់អ្នកទាំងពីរ មិនអាចធ្វើឲ្យអ្នកទាំងពីរបដិសេធការអនុវត្តភារកិច្ចបាន ។ ឌុច បាននិយាយថា "បើទោះបីជាខ្ញុំមិនចូលចិត្តការងារប៉ូលីស និងការសួរចម្លើយ ប៉ុន្តែប្រសិនបើគម្រូវឲ្យខ្ញុំធ្វើការងារនេះ ខ្ញុំនឹងធ្វើឲ្យល្អជាង ណាត [អតីតប្រធានមន្ទីរស-២១ មុខពេល ឌុច ក្លាយជាប្រធាន] ទៅទៀត ។ ខ្ញុំត្រូវតែធ្វើ ។ ខ្ញុំមិនអាចជៀសវាងបាន ។ នេះគឺជាបញ្ជា ដែលខ្ញុំត្រូវតែអនុវត្ត ។"

អ្នកទាំងពីរយកចិត្តទុកដាក់ពីការផ្គាប់ចិត្ត និងគោរពថ្នាក់លើរបស់ខ្លួន ។ នៅពេលដែលថ្នាក់លើជឿទុកចិត្ត និងប្រគល់ការងារមកឲ្យ អ្នកទាំងពីរត្រូវតែអនុវត្តបទបញ្ជានោះឲ្យបានល្អ ដោយសារតែថ្នាក់លើជាតំណាងឲ្យច្បាប់ ។ នៅក្នុងការសំដែងរឿងរ៉ាវដែលបានកើតឡើងឡើងវិញនៅវាលពិឃាតជើងឯក ឌុច បាននិយាយប្រាប់ថា "នៅពេលនោះ យើងហៅវាថាជាភារកិច្ច ។ ប៉ុន្តែ សម្រាប់តុលាការកាត់ទោសមេដឹកខ្មែរក្រហម ភារកិច្ចដែលយើងបានអនុវត្តតាម គឺជាបទឧក្រិដ្ឋទៅវិញ ។" អៃក្មាន់

---

[៦] នៅក្នុងសង្គ្រាមលោកលើកទីពីរ អាឌុល អៃក្មាន់ (Adolph Eichmann) គឺជាប្រធានការិយាល័យកណ្តាលរបស់ណាហ្ស៊ីសម្រាប់ជនភៀសខ្លួនជ្វីហ និង "ជាបុគ្គលសំខាន់មួយរូបនៅក្នុងការនិរទេសប្រជាជនជ្វីហជាងមួយលានប្រាំសែននាក់ពីគ្រប់ប្រទេសនៅទ្វីបអឺរ៉ុបទៅកាន់មន្ទីរ និងកន្លែងសម្លាប់នៅប្រទេសប៉ូឡូញ និងផ្នែកខ្លះនៃសហភាពសូវៀត ។" អៃក្មាន់ ត្រូវបាននាំទៅកាត់ទោសប្រហារ ជីវិតនៅប្រទេសអ៊ីស្រាអែលអំពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ សារមន្ទីរហូឡូខសសហរដ្ឋអាមេរិក Holocaust Encyclopedia, http://www.ushmm.org/wlc/en/article.php?ModuleId=10007412

[៧] ពីឆ្នាំ១៩៧១ ដល់ឆ្នាំ១៩៧៥ ឌុច គឺជាប្រធានមន្ទីរសន្តិសុខម១៣របស់ខ្មែរក្រហម ដែលគាត់ទទួលខុសត្រូវលើការ"សួរចម្លើយជនដែលជាប់សង្ស័យថាជាអ្នកស៊ើបការណ៍ ឬជាខ្មាំងប្រឆាំងនឹងបក្សកុម្មុយនីស្តកម្ពុជា ។" Case No. 001/18-07-2007-ECCC/TC, Judgment ¶ 115 (July 26 2010). Similar to S-21, many—though not all—of the detainees were tortured and executed after their interrogations. See id. ¶ 115 ។

[៨] HANNAH ARENDT, Eichmann in Jerusalem ការបោះពុម្ពជាភាសាបារាំងៈ Folio-Histoire, ទំព័រទី១៣០ និង១៧៤ ។

ហាក់បាននិយាយសម្ដីស្រដៀងនឹង ឌុច ដែរ «អ្វីដែលគាត់ធ្លាប់បានធ្វើគឺជាបទឧក្រិដ្ឋ ។ ប៉ុន្តែ គាត់តែងតែព្យាយាមធ្វើជាពលរដ្ឋមួយរូបដែលគោរពច្បាប់ ដោយធ្វើតាមបទបញ្ជារបស់អ៊ីថ្លៃ ដែលបទបញ្ជានោះគឺជាច្បាប់ ។»[៩]

ប៉ុន្តែ នៅពេលដែលបរិបទផ្លាស់ប្ដូរ អ្នកទាំងពីរត្រូវបានចោទប្រកាន់ចំពោះបទឧក្រិដ្ឋនៃទង្វើរបស់ខ្លួន ។ អៃក្មាន់ បានលើកឡើងថា «ការកម្ទេចជនជាតិជ្វីហ្វគឺជាឧក្រិដ្ឋកម្មមួយដ៏ធ្ងន់ធ្ងរនៅក្នុងប្រវត្តិសាស្ត្ររបស់មនុស្សជាតិ ។»[១០] ឌុច បាននិយាយស្រដៀងគ្នានឹង អៃក្មាន់ នៅក្នុងសវនាការបឋម និងនៅក្នុងសវនាការបន្ទាប់មកទៀតថា «ខ្ញុំចង់ប្រាប់ទៅកាន់ពិភពលោកទាំងមូលឲ្យបានដឹងអំពីមន្ទីរស-២១ ។ ប៉ុន្តែ វាជារឿងមួយដ៏វែង ។ ដូច្នេះ ខ្ញុំសូមសង្ខេបដោយខ្លីថា ឧក្រិដ្ឋកម្មដែលបានកើតឡើងនៅមន្ទីរស-២១មានលក្ខណៈធ្ងន់ធ្ងរ ជាប្រព័ន្ធ និងបានរៀបចំយ៉ាងត្រឹមត្រូវ ។»

អ្នកទាំងពីរបានប្រើយុទ្ធសាស្ត្រស្រដៀងគ្នា ។ យើងដឹងថានៅក្នុងសវនាការទាំងមូល ឌុច បានបង្ហាញពីការស្ដាយក្រោយជាបន្តបន្ទាប់ ប៉ុន្តែនៅក្នុងសវនាការថ្ងៃចុងក្រោយ ឌុច បានសុំឲ្យតុលាការសម្រេចថាខ្លួនគ្មានកំហុស ។ ចំណែកឯ អៃក្មាន់ វិញ គាត់បានព្យាយាមពន្យល់ជាច្រើនលើកច្រើនសារថា អ្វីដែលអាក្រក់បំផុតសម្រាប់គាត់ គឺការរត់គេចពីការទទួលខុសត្រូវ ប៉ុន្តែគាត់បែរជាស្នើសុំឲ្យមានការបន្ធូរបន្ថយទោសទៅវិញ ។[១១]

អ្នកទាំងពីរហាក់ដូចជាបានជួបប្រទះនូវហេតុការណ៍ដ៏គួរឲ្យក្រៀមក្រំ ។ ឌុច បានលើកឡើងថាខ្លួនបានរស់នៅក្នុងភាពជុនដាប ហើយរង់ចាំថ្ងៃដែលគាត់ត្រូវបានកម្ទេចមកដល់ ។ មិនខុសគ្នាពី ឌុច ប៉ុន្មាន អៃក្មាន់ បាននិយាយបន្ទាប់ពីខ្លួនបានដឹងពីអត្ថន័យដ៏គួរឲ្យខ្លាចរបស់ពាក្យ «ដំណោះស្រាយចុងក្រោយ» ថា «ខ្ញុំបានអង្គុយនៅក្នុងរថយន្តរបស់ខ្ញុំនៅជិតនឹងអ្នកបើករថយន្តឲ្យខ្ញុំអស់រយៈពេលជាច្រើនម៉ោង ។ យើងមិនបាននិយាយឆ្លើយឆ្លងគ្នាសូម្បីតែមួយម៉ាត់ ។ នៅពេលនោះ ខ្ញុំយល់ថាខ្ញុំទទួលបានអ្វីៗគ្រប់គ្រាន់ហើយ ។ ចប់ហើយខ្ញុំ ។»[១២]

ចំពោះចំណុចខុសគ្នារវាងអ្នកទាំងពីរវិញគឺ ឌុច បានរស់នៅក្បែរនឹងទីតាំងដែលបទឧក្រិដ្ឋបានកើតឡើង ។ នេះបានបង្កឲ្យមានចម្ងល់ថា តើ ឌុច ពិតជាបានចូលរួមប្រព្រឹត្តនូវបទឧក្រិដ្ឋនោះដោយផ្ទាល់ឬយ៉ាងណា ។ ឌុច តែងតែប្រកាសថា «ខ្ញុំសូមទទួលខុសត្រូវចំពោះរឿងរ៉ាវទាំងឡាយដែលបាន

---

[៩] ដដែលដូចខាងលើ, ទំព័រទី៧៨ ។

[១០] ដដែលដូចខាងលើ, ទំព័រទី៧៥ ។

[១១] ដដែលដូចខាងលើ, ទំព័រទី១២៧ ។

[១២] ដដែលដូចខាងលើ, ទំព័រទី១៨១ ។

កើតឡើងនៅមន្ទីរស-២១ ។" ប៉ុន្តែ ឌុច មិនបានព្យាយាមឆ្លើយសំណួររបស់យើងដែលទាក់ទងនឹងសកម្មភាពរបស់គាត់នោះទេ ។

ឌុច បានបដិសេធថាមិនធ្លាប់បានធ្វើទារុណកម្មអ្នកទោសដោយផ្ទាល់ ប៉ុន្តែ ឌុច បានទទួលស្គាល់ដោយអល់ឯកថា ខ្លួនធ្លាប់បាន"ទះអ្នកទោសពីរបីដៃ ។" ការលើកឡើងនេះហាក់ដូចជាខុសពីអ្វីដែលបុគ្គលិករបស់ ឌុច ធ្លាប់បានលើកឡើង ។ បុគ្គលិកម្នាក់របស់ ឌុច បានអះអាងថា ឌុច ធ្លាប់បានធ្វើទារុណកម្មអ្នកទោសស្រីម្នាក់តាំងពីម៉ោង៩យប់ ដល់ម៉ោង៣ព្រឹក ដោយឆក់ខ្សែភ្លើង រហូតដល់អ្នកទោសស្រីនោះសន្លប់ ។ ប៉ុន្តែ ឌុច បានបដិសេធការអះអាងនោះ ។

ឌុច មិនបានបដិសេធចំពោះការជាប់ពាក់ព័ន្ធរបស់គាត់ទៅនឹងរឿងធ្វើទារុណកម្មអ្នកទោស ដែលប្រព្រឹត្តដោយបុគ្គលិកនោះឡើយ ។ ប៉ុន្តែ ឌុច ហាក់ដូចជាធ្វើឲ្យការលើកឡើងនេះឲ្យក្លាយទៅជារឿងដែលគួរឲ្យស្មុគស្មាញ ។ នៅពេលដែលសួរ ឌុច អំពីចំណាររបស់ខ្លួននៅលើឯកសារមួយទាក់ទងនឹងករណី អួម សឿន, ឌុច បានសិក្សាឯកសារនោះដោយយកចិត្តទុកដាក់មុនពេលគាត់ទទួលស្គាល់ថាគាត់ពិតជាបានចារនៅលើឯកសារនោះមែន ។ ឌុច បានចារថា "នៅមិនទាន់ឆ្លើយសារភាព ។ ត្រូវធ្វើទារុណកម្ម ។" ដោយឡែក នៅលើឯកសារមួយផ្សេងទៀត ដែលពាក់ព័ន្ធនឹងករណីស្ត្រីម្នាក់ឈ្មោះ ដាញ់ ស៊ីយ៉ាន មានចំណារថា "ត្រូវសួរចម្លើយឲ្យបានល្អិតល្អន់ និងធ្វើទារុណកម្មឲ្យធ្ងន់ល្មម ដើម្បីស្វែងរកឲ្យឃើញនូវបក្សពួក ។ វាយនាងរហូតដល់នាងឈប់ឆ្លើយថា នាងធ្លាប់បានទៅប្រទេសវៀតណាមជាមួយជីតារបស់នាង ដើម្បីព្យាបាលជំងឺមហារីក និងជំងឺរដូវមិនទៀងទាត់ ។"

ឌុច បានបញ្ជាក់ថា គាត់បានសរសេរចំណារដោយខ្លួនឯង ។ ប៉ុន្តែ គាត់ចង់បកស្រាយអំពីចំណារនេះ ហើយចង់ឲ្យយើងស្តាប់ការបកស្រាយរបស់គាត់ៈ

> "ឯកសារមួយនេះចុះនៅថ្ងៃទី៨ ខែមករា ឆ្នាំ១៩៧៦ គឺនៅពេលដែល ណាត មើលការខុសត្រូវគ្រប់យ៉ាង ។ ចំណែកឯរូបខ្ញុំវិញ គឺធ្វើតាមការបញ្ជារបស់គាត់ ។ ណាត បានកែរបាយការណ៍របស់ខ្ញុំ មុនពេលផ្ញើឲ្យទៅ សុន សេន ។ នៅពេលដែលខ្ញុំត្រូវបានតែងតាំងជាប្រធានមន្ទីរស-២១ អ្វីៗទាំងអស់ត្រូវបានកែប្រែ ។ ចំពោះការធ្វើទារុណកម្ម ត្រូវធ្វើឡើងដូចតទៅៈ ហ៊ីរ គឺជាអ្នកទទួលខុសត្រូវចំពោះទាហានសាមញ្ញ និងមានសិទ្ធិបញ្ជាឲ្យធ្វើទារុណកម្ម ។ ចំពោះអ្នកទោសសំខាន់ៗ ដូចជា យ៉ា ជាដើម សុន សេន បានប្រគល់សិទ្ធិឲ្យខ្ញុំ ។ ខ្ញុំអាចបញ្ជាឲ្យធ្វើទារុណកម្មបាន ។"

បើនិយាយក្នុងន័យផ្សេង ឌុច គឺជាកម្មាភិបាលមួយរូបដែលមានឋានៈខ្ពស់ និងមិនអាចជាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្មអ្នកទោសនោះទេ ។ ស្របពេលជាមួយគ្នានេះដែរ ឌុច ក៏មិនមែនជាកម្មាភិបាលជាន់ខ្ពស់ ដែលមានសិទ្ធិចេញបញ្ជាឲ្យធ្វើទារុណកម្មទៅលើនរណាម្នាក់នោះដែរ ។

ស្រដៀងគ្នាទៅនឹងការលើកឡើងខាងលើ បើទោះបីជា ឌុច គឺជាប្រធានមន្ទីរសន្តិសុខមួយដែលបង្កើតឡើងសម្រាប់ការសម្លាប់អ្នកទោសជាលក្ខណៈប្រព័ន្ធក៏ដោយ ក៏ ឌុច មិនដែលចេញសេចក្តីសម្រេចចិត្តណាមួយឲ្យសម្លាប់អ្នកទោសណាម្នាក់នោះឡើយ ។ នៅពេលដែលយើងបង្ហាញឯកសារចម្លើយសារភាពមួយ ដែល ឌុច បានចារដោយដៃគាត់ផ្ទាល់ថាឲ្យយកអ្នកទោសនោះទៅសម្លាប់ ឌុច បានបកស្រាយទៅលើចំណារនោះ ដោយលើកឡើងថា នោះគឺជាតួនាទីរបស់គាត់ ដែលត្រូវតែអនុវត្តតាមការបញ្ជា ។ នៅថ្ងៃមួយ គាត់បាននិយាយប្រាប់យើងថាៈ

"គោលការណ៍ទូទៅនៅក្នុងមន្ទីរសន្តិសុខ ក៏ដូចជាមន្ទីរស-២១ បានចែងថា ជនដែលបានចាប់ខ្លួនគឺគួរតែសម្លាប់ ។ ដូច្នេះ ការសម្រេចចិត្តដែលធ្វើឡើងនៅមន្ទីរសន្តិសុខមានតែមួយប៉ុណ្ណោះ គឺពេលណាដែលអ្នកទោសត្រូវយកទៅសម្លាប់ ។ បុគ្គលដែលទទួលខុសត្រូវចំពោះការសម្លាប់ គឺ ហ៊ីរ ។ មុនពេលសម្លាប់អ្នកទោស ខ្ញុំត្រូវប្រាកដថាការសួរចម្លើយត្រូវបានអនុវត្តចប់សព្វគ្រប់ ។ បន្ទាប់មក ហ៊ីរ នឹងបញ្ជូនបញ្ជីអ្នកទោសដែលនឹងត្រូវយកទៅសម្លាប់មកឲ្យខ្ញុំ ដើម្បីឲ្យខ្ញុំពិនិត្យផ្ទៀងផ្ទាត់ថា ការសួរចម្លើយទៅលើអ្នកទោសទាំងនោះពិតជាបានចប់សព្វគ្រប់ ។ បន្ទាប់មក ខ្ញុំចុះហត្ថលេខានៅលើបញ្ជីនោះ ហើយ ហ៊ីរ ជាអ្នកអនុវត្តសេចក្តីសម្រេចយកអ្នកទោសទៅសម្លាប់ ។"

ពីរបីថ្ងៃមុនពេលដែលរបបខ្មែរក្រហមត្រូវបានផ្តួលរំលំ នៅថ្ងៃទី២ ឬថ្ងៃទី៣ ខែមករា ឆ្នាំ ១៩៧៩ នួន ជា បានហៅ ឌុច ឲ្យមកជួប និងបានបញ្ជាឲ្យ ឌុច សម្លាប់អ្នកទោសទាំងអស់នៅមន្ទីរ ស-២១ ។ នៅពេលដែលសួរ ឌុច ថា តើមានព្រឹត្តិការណ៍អ្វីកើតឡើង ។ ឌុច បានឆ្លើយថា "ខ្ញុំមានការតក់ស្លុតចំពោះសំណួរមួយនេះ ។ ខ្ញុំបាននិយាយប្រាប់ ហ៊ីរ អំពីបទបញ្ជានេះ ។"

សហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង បានសួរបញ្ជាក់ "តើលោកប្រាប់គាត់ ឬលោកបញ្ជាគាត់?"

"ខ្ញុំប្រាប់គាត់ ។ បន្ទាប់ពីបានប្រាប់ ហ៊ីរ រួចហើយ ខ្ញុំបានទៅសម្រាន្ត ដោយសារតែខ្ញុំពុំមានសល់ក្តីសង្ឃឹមអ្វីទាំងអស់ ។ ខ្ញុំសូមបញ្ជាក់បន្ថែមត្រង់កន្លែងនេះថា ខ្ញុំបានក្លាយទៅជាមនុស្សម្នាក់ដែលពុំមានក្តីសង្ឃឹមអ្វីទាំងអស់រួចទៅហើយ មុនពេលដែលខ្ញុំបានទទួលបទបញ្ជានោះទៅទៀត ។"

ដូច្នេះ មានន័យថា ឌុច បានប្រាប់បុគ្គលិករបស់គាត់អំពីបទបញ្ជាដែលគាត់បានទទួលពីថ្នាក់លើ ។ បើយើងក្រឡេកមើលទៅ ឌុច ហាក់ដូចជាធ្វើការនៅក្នុងផ្នែកសារព័ត៌មាន ។ គាត់បានបញ្ជូន

ព័ត៌មានពីថ្នាក់លើមកឲ្យថ្នាក់ក្រោម និងបញ្ជូនឯកសារចម្លើយសារភាពដែលថ្នាក់ក្រោមបានផ្ញើទៅឲ្យថ្នាក់លើវិញ ។

នៅក្នុងការសួរចម្លើយកាលពីខែសីហា ឆ្នាំ២០០៧ ខ្ញុំបានប្រឈមមុខជាមួយ ឌុច អំពីភាពផ្ទុយគ្នារបស់គាត់ ។

"ជាសរុប លោកគឺជាប្រធានមួយរូបដែលគ្មានអំណាច និងមិនធ្លាប់ចេញសេក្តីសម្រេចចិត្តណាមួយដោយខ្លួនឯងនោះទេ ។ កាតព្វកិច្ចរបស់លោកគឺគ្រាន់តែបញ្ជូនបទបញ្ជាពីថ្នាក់លើ ហើយនៅទីបញ្ចប់ (ចាប់ពីចុងឆ្នាំ១៩៧៨ ដល់ឆ្នាំ១៩៧៩) លោកមិនបានដឹងអ្វីទាំងអស់ដែលបានកើតឡើងនៅមន្ទីរស-២១ ។ មិនមាននរណាម្នាក់បានបញ្ជូនព័ត៌មានអ្វីទាំងអស់ឲ្យលោក ដែលទាក់ទងទៅនឹងអ្វីដែលបានកើតឡើងនៅទីនោះ?"

"ខ្ញុំមានអំណាចក្នុងការរាយការណ៍ពីទំនាក់ទំនងរវាងថ្នាក់លើ និងបញ្ជូនព័ត៌មានទៅកាន់ថ្នាក់ក្រោម ។ មិនតិចមិនច្រើន ។ នៅពេលដែលមន្ទីរស-២១ ត្រូវបានបង្កើតឡើង តួនាទីរបស់ខ្ញុំមានត្រឹមតែអានឯកសារចម្លើយសារភាព និងរាយការណ៍ប្រាប់ សុន សេន តាមរយៈទូរស័ព្ទរៀងរាល់ថ្ងៃអំពីអ្វីដែលខ្ញុំបានធ្វើ ។ នៅពេលដែល សុន សេន ចាកចេញទៅ ខ្ញុំបានបញ្ជូនព័ត៌មានទាំងនេះទៅឲ្យ នួន ជា រៀងរាល់បីទៅបួនទៅប្រាំថ្ងៃម្តង ។ ខ្ញុំមានអំណាចក្នុងការរាយការណ៍គ្រប់ទំនងទំនងទាំងអស់ពីថ្នាក់លើ និងបែកចាយបន្តទៅថ្នាក់ក្រោម ។ ខ្ញុំគ្រាន់តែជាប្រធានដែលមានតែនាមតែប៉ុណ្ណោះ ។"

ប្រធានដែលមានតែនាម? ឌុច នឹងមិននិយាយអ្វីផ្ទុយនោះទេ ប្រសិនបើគាត់ប្រើនូវយុទ្ធសាស្ត្រការពារខ្លួនស្រដៀងទៅនឹងយុទ្ធសាស្ត្រដែល ខៀវ សំផន ប្រើ ។ ឌុច បានប្រឌិតថា អំណាចរបស់ខ្លួនមានតែនៅលើក្រដាសតែប៉ុណ្ណោះ ។ ពោលគឺមិនមែនអំណាចពិតប្រាកដនោះទេ ។ ផ្ទុយពី ខៀវ សំផន, ឌុច មិនបានព្យាយាមរត់គេចពីការដាក់ទណ្ឌកម្មនោះទេ ។ គាត់ព្រមទទួលខុសត្រូវរាល់ឧក្រិដ្ឋកម្មទាំងអស់ដែលបានកើតឡើងនៅមន្ទីរស-២១ ។

ស្ថិតនៅក្នុងស្ថានភាពពិតជាក់ស្តែង ឌុច ប្រហែលជាជួបការលំបាកក្នុងការប្រឈមមុខនឹងអតីតកាលរបស់គាត់ ។ ឌុច ជាបុគ្គលមួយរូបដែលគ្រប់គ្រងអំណាចទាំងអស់នៅមន្ទីរស-២១ និងជាបុគ្គលតែម្នាក់គត់ ។ នេះជារឿងមួយដែលមិនអាចប្រកែកបាន ។ យ៉ាងហោចណាស់ បុគ្គលិកមន្ទីរស-២១ ចំនួន៦៤នាក់ត្រូវបានសម្លាប់នៅវាលពិឃាតជើងឯក និងបុគ្គលិកមួយចំនួនផ្សេងទៀតត្រូវបានសម្លាប់នៅទួលស្លែង ។ នៅក្នុងបរិបទនេះ មិនមានបុគ្គលណាម្នាក់បានព្យាយាមបញ្ឈប់ទង្វើរបស់ ឌុច នោះទេ ។ ដូច្នេះ ការដែលលើកឡើងថា គាត់គ្រាន់តែជា "ប្រធានដែលមានតែនាម" មួយរូបនោះ គឺជាការលើកឡើងមួយដែលមិនអាចទទួលយកបាននោះទេ ។

នៅពេលដែល ឌុច និយាយថាខ្លួនព្រមទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងឡាយដែលបានកើតឡើងនៅមន្ទីរស-២១ ប្រហែលជាគាត់បាននិយាយការពិត ។ ប៉ុន្តែ នៅពេលដែល ឌុច និយាយថាខ្លួនមិនដែលសម្លាប់នរណាម្នាក់ វាហាក់ដូចជាមិនគួរឲ្យជឿ ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ការដោះសារនេះមិនបានធ្វើឲ្យប៉ះពាល់ដល់ភាពស្មោះត្រង់របស់គាត់ទៅលើការសារភាពទទួលខុសត្រូវនោះទេ ។ មានករណីជាច្រើន ដែលជនជាប់ចោទបានសារភាពទទួលស្គាល់បទឧក្រិដ្ឋដែលខ្លួនបានប្រព្រឹត្ត ប៉ុន្តែបានបដិសេធមិនព្រមរៀបរាប់ហេតុការណ៍លំអិត ។ នេះគឺជាចរិតធម្មជាតិរបស់មនុស្ស ។ ការទទួលស្គាល់កំហុសមិនមែនជារឿងលំបាកនោះទេ ប៉ុន្តែការសារភាពនូវកំហុសដែលបានកើតឡើងគឺជារឿងមួយដែលពិបាក ។

ដូចដែលអ្នកជំនាញបានលើកឡើង យើងហាក់ដូចជាទាល់គំនិត ។ យើងមិនដឹងថាការបង្ហាញអារម្មណ៍វិប្បដិសារីរបស់ ឌុច ធ្វើឡើងដោយភាពស្មោះត្រង់ឬយ៉ាងណានោះទេ ។ នៅក្នុងករណីរបស់ឌុច ភាពកហុកភូតភរហាក់ដូចជាបានឈរនៅពីក្រោយការពិត ។ ឌុច ក៏មិនអាចរកឃើញនូវចម្លើយសម្រាប់ចម្ងល់ដែលបានលើកឡើងនោះទេ ដោយសារតែគាត់ត្រូវបានហ៊ុមព័ទ្ធដោយអតីតកាល ។ ឌុចត្រូវតែរស់នៅជាមួយអ្វីដែលខ្លួនបានប្រព្រឹត្ត ហើយនេះជាអ្វីដែលមនុស្សទូទៅមិនអាចធ្វើបាន ។